ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

# សេចក្តីប្រកាសព័ត៌មានរបស់
# ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ (កបទ.សអ) នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានរំខានដោយ និងសូមច្រានចោលការចេញផ្សាយព័ត៌មានរបស់អ្នករាយការណ៍ពិសេសចំនួនបីរូប កាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០ ក្រោមហេតុផលនយោបាយនិងមានបំណងបំភ័ន្តសាធារណជន អំពីដំណើរការសវនាការលើជនជាប់ចោទ លោក កឹម សុខា។

ដូចពេលកន្លងមកដែរ កបទ.សអ សូមសម្តែងនូវការសោកស្តាយជាពន់ពេកចំពោះការប្រព្រឹត្តិមិនស្របតាមវិជ្ជាជីវៈរបស់អ្នកជំនាញខាងលើ ដែលមិនមែនជាមន្ត្រីអង្គការសហប្រជាជាតិ និងគ្រាន់តែបំពេញការងារក្នុងឋានៈផ្ទាល់ខ្លួន ប៉ុន្តែតាំងខ្លួនជាចៅក្រមនៅក្នុងកិច្ចការតុលាការនិងផ្ទៃក្នុងរបស់រដ្ឋអធិបតេយ្យមួយ។ កបទ.សអ សូមរំលឹកអ្នកជំនាញទាំងនោះថា នៅប្រទេសកម្ពុជា ក៏ដូចសង្គមប្រជាធិបតេយ្យដ៏ទៃទៀត បុគ្គលបំពានច្បាប់ត្រូវរងការចោទប្រកាន់និងកាត់ទោស ដោយឈរលើមូលដ្ឋាននៃបទល្មើសដែលបានប្រព្រឹត្ត និងមិនផ្អែកលើឋានៈនយោបាយឡើយ។ ឋានៈជាអ្នកនយោបាយ មិនថាស្ថិតនៅក្រោមស្លាកបក្សប្រឆាំងឬអត់ ពុំបានផ្តល់សិទ្ធិឱ្យបុគ្គលនោះធ្វើសកម្មភាពដោយនិទណ្ឌភាពទេ។ ហេតុផលបុគ្គលឬនយោបាយមិនអាចប្រើប្រាស់ជាទឡ្ហីករណ៍សម្រាប់ការប្រព្រឹត្តិបទល្មើសឡើយ។ បទចោទលើ លោក កឹម សុខា មានចែងយ៉ាងច្បាស់នៅក្នុងមាត្រា ៤៤៣ នៃក្រមព្រហ្មទណ្ឌរបស់កម្ពុជា ហើយវិធានការច្បាប់ចំពោះគាត់នាពេលកន្លងមក បានត្រូវអនុវត្តស្របតាមច្បាប់ពាក់ព័ន្ធរបស់ប្រទេសរួមទាំងរដ្ឋធម្មនុញ្ញ។

ការនិយាយយោងរបស់អ្នករាយការណ៍ពិសេសទៅនឹងទស្សនៈរបស់ "ក្រុមការងារស្តីពីការឃុំខ្លួនតាមអំពើចិត្ត" (ហៅកាត់ថា " ក្រុមការងារ ") ដែលជាបណ្តុំបុគ្គលប្រាំរូបរួមគ្នា មិនត្រឹមតែពុំមានសំអាងត្រឹមត្រូវ ហើយថែមទាំងបង្កអោយមានការភ័ន្តច្រឡំទៀត។ បុគ្គលទាំងប្រាំរូបពុំមែនជាមន្ត្រីអង្គការសហប្រជាជាតិ គ្រាន់តែបំពេញការងារក្នុងឋានៈផ្ទាល់ខ្លួន ដែលពុំមានការយល់ដឹងជាក់ស្តែងស្តីពីស្ថានភាពច្បាប់និងនយោបាយរបស់ប្រទេសកម្ពុជា។ ទស្សនៈឬសេចក្តីសន្និដ្ឋានរបស់ "ក្រុមការងារ" នេះពុំមានទម្ងន់អ្វីទាល់តែសោះ រាប់ទាំងទម្ងន់ផ្លូវច្បាប់ មកលើរដ្ឋអធិបតេយ្យមួយ ហើយកបទ.សអ សូមបដិសេធចំពោះសេចក្តីសន្និដ្ឋានរបស់ " ក្រុមការងារ " នេះ ដែលពុំបានគោរពតាមរបៀបរបបធ្វើការងារត្រឹមត្រូវ។

អាសយដ្ឋានៈ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

ការចោទប្រកាន់ថា លោក កឹម សុខា ត្រូវបានឃុំខ្លួនលើសរយៈពេលកំណត់ដោយច្បាប់ គឺជាការបំផ្លើស និងបង្ហាញយ៉ាងច្បាស់អំពីការយល់ដឹងនៅមានកម្រិត ឬពុំមានឆន្ទៈចង់យល់អំពីនីតិវិធីតុលាការរបស់ប្រទេសកម្ពុជា ពីសំណាក់អ្នកជំនាញទាំងនោះ។ ការពិតគឺថា លោក កឹម សុខា បានត្រូវដោះលែងកាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៨ ក្រោមការត្រួតពិនិត្យផ្លូវតុលាការ ដោយមានលក្ខខណ្ឌជាក់លាក់។ នេះមានន័យថា គាត់ពុំស្ថិតក្រោមរបបនៃការឃុំខ្លួនមុនសវនាការ ដែលមានរយៈពេលអតិបរមា១៨ខែនោះឡើយ។ លោក កឹម សុខា ពុំស្ថិតក្នុងការឃុំឃាំងក្នុងផ្ទះទេ។ កបទ.សអ សូមរំលឹកអ្នកជំនាញអោយប្រើប្រាស់វាក្យស័ព្ទច្បាប់ឱ្យបានត្រឹមត្រូវនៅក្នុងសេចក្តីថ្លែងការណ៍របស់ខ្លួន ប្រសិនបើពុំមានបំណងធ្វើឱ្យសាធារណជនយល់ខុសនិងភ័ន្តច្រឡំ។ ដោយស្ថិតនៅជាជនជាប់ចោទនៅឡើយ លោក កឹម សុខា ពុំអាចធ្វើដំណើរចាកចេញពីព្រំដែនកម្ពុជា ហើយមិនត្រូវចូលរួមក្នុងសកម្មភាពនយោបាយណាមួយទេ។

ការចោទប្រកាន់របស់អ្នករាយការណ៍ពិសេសខាងលើអំពីកង្វះការចូលរួមជាសាធារណៈនៅក្នុងបន្ទប់សវនាការ បង្ហាញយ៉ាងច្បាស់ថា ការវាយតម្លៃរបស់អ្នកជំនាញទាំងនោះអំពីកម្ពុជាបានផ្អែកលើតែប្រភពព័ត៌មានពុំបានផ្ទៀតផ្ទាត់និងមិនអាចទុកចិត្តបាន។ នៅគ្រប់ប្រទេសប្រជាធិបតេយ្យទាំងអស់ ការសម្រេចអោយចូលទៅក្នុងបន្ទប់សវនាការតែងតែជាឆន្ទានុសិទ្ធិរបស់តុលាការ ដោយពិចារណាលើទំហំជាក់ស្តែងនៃបន្ទប់សវនាការ សណ្តាប់ធ្នាប់ និងការប្រព្រឹត្តិទៅនៃការជំនុំជម្រះ។ មានតំណាងអង្គទូតជាច្រើនចូលរួម ហើយពុំមានកៅអីនៅសល់ទំនេរទុកចោលទេ។ កបទ.សអ យល់ថា ការលើកឡើងរបស់អ្នករាយការណ៍ពិសេសថា កង្វះខាតការចូលរួមជាសាធារណៈនៅក្នុងបន្ទប់សវនាការ មានន័យស្មើនឹងកង្វះយុត្តិធម៌ គឺជាការចំអកលើបទដ្ឋាននៃវិជ្ជាជីវៈច្បាប់និងតុលាការទាំងស្រុង។

ជាចុងក្រោយ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ទទូចដល់អ្នករាយការណ៍ពិសេសទាំងអស់ គោរពឱ្យបានខ្ជាប់ខ្ជួននូវ "ក្រមប្រតិបត្តិសម្រាប់តំណាងអាណត្តិនៃនីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស" នៅពេលបំពេញមុខងារខ្លួន រួមទាំងការចេញសេចក្តីថ្លែងការណ៍សាធារណៈដែលអាចត្រូវបកស្រាយថា ជាការជ្រៀតជ្រែកក្នុងប្រព័ន្ធយុត្តិធម៌កម្ពុជា៕

ថ្ងៃសុក្រ ៨រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០២០